**រដ្ឋាភិបាលជាតិខ្មែរនិរទេស**
**ជាតិ សាសនា ប្រជាជាតិខ្មែរ**

ក្រសួងការបរទេស
លេខ.០០១/១៦.កកប.រជខន

# សេចក្តីប្រកាសព័ត៌មាន

**ក្រសួងការបរទេស** មានកិត្តិយស សូមជម្រាបជូនដល់សាធារណជន សារព័ត៌មានជាតិ និងអន្តរជាតិ ឱ្យបានជ្រាបថា នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៦ ខាងមុខនេះ លោក **សម សេរី** នាយករដ្ឋមន្ត្រី នៃរដ្ឋាភិបាលជាតិខ្មែរនិរទេស នឹងអញ្ជើញចូលជួប លោក **ERIK LAURSEN** ប្រធានទទួលបន្ទុកកិច្ចការអាស៊ីនៃក្រសួងការបរទេសដាណឺម៉ាក ដើម្បីពិភាក្សា បញ្ហារំលោភសិទ្ធិមនុស្សក្នុងប្រទេសខ្មែរ និងការឈ្លានពានរបស់ប្រទេសវៀតណាម ក្នុងការបោះបង្គោលព្រំដែនលើទឹកដីខ្មែរតាមសន្ធិសញ្ញាខុសច្បាប់ឆ្នាំ១៩៨៥។

លោកនាយករដ្ឋមន្ត្រី នឹងលើកយកបញ្ហារំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរនៅកម្ពុជា ដូចជាការរឹបអូសដីធ្លី ការបណ្តេញចេញពីលំនៅស្ថាន ការបាញ់សម្លាប់កម្មករ ការចាប់ដាក់ពន្ធនាគារដោយអយុត្តិធម៌ (សកម្មជនសិទ្ធិមនុស្ស គណបក្សប្រឆាំង អ្នកការពារបរិស្ថាន និងសមាជិករណសិរ្សរំដោះជាតិខ្មែរ) និងជាពិសេសរឿងប្តូរខ្នាតផែនទីបោន (BONNE) ខ្នាត១/១០០.០០០ ដែលទទួសស្គាល់ដោយអង្គការសហប្រជាជាតិ មកជាផែនទីយូ.ធី.អឹម (UTM) ខ្នាត១/៥០.០០០ ដែលបង្ហាញពីការឈ្លានពានជាក់ស្តែងរបស់ប្រទេសវៀតណាម និងការរួមគំនិតរបស់គណបក្សប្រជាជនកម្ពុជា ហ៊ុន សែន និង គណបក្សសង្គ្រោះជាតិ សម រង្ស៊ី ក្នុងការធ្វើឱ្យបាត់បង់ទឹកដីខ្មែរទៅប្រទេសវៀតណាម ដែលផ្ទុយពីស្មារតីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន សារព័ត៌មានជាតិ និងអន្តរជាតិ ជ្រាបជាព័ត៌មាន៕

ធ្វើនៅទីក្រុងកេបិក ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៦
រដ្ឋមន្ត្រីក្រសួងការបរទេស

**យុន ចាន់តូ**

➢ **ព័ត៌មានលំអិតសូមទាក់ទង**
**Tel.: +1 (418) 990 0496**
**E-mail: mfa@kngexile.org**
**Facebook: www.facebook.com/mfakngexile**

ទីស្នាក់ការកណ្តាលបណ្តោះអាសន្នរបស់ .ស.រ.ជ.ខ, ប្រអប់សំបុត្រលេខ ៣៣៩០, ហ៊ុនិស្ទីល ប្រទេសដាណឺម៉ាក
Temporary Headquarter of K.N.G.E. : P.O. Box 3390, Hundested, Denmark
Tel: (+45) 7184 8379; E-mail: primeministerinexile@gmail.com; website: www.kngexile.org